# កិច្ចប្រជុំពេញអង្គលើកទី៧ របស់ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ថ្ងៃទី២ ដល់ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ ២០១០

## សេចក្តីប្រកាសព័ត៌មានរបស់អង្គភាពគាំពារការការពារក្តី

1. អង្គភាពគាំពារការការពារក្តី (DSS) បានចូលរួមក្នុងកិច្ចប្រជុំពេញអង្គក្នុងសប្តាហ៍នេះ ក្នុងឋានៈជាសមាជិកដែលគ្មានសិទ្ធបោះឆ្នោត ដែលនៅក្នុងកិច្ចប្រជុំនោះបានសម្រេចលើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

2. ចៅក្រម និងព្រះរាជអាជ្ញា បានអនុម័តលើការធ្វើវិសោធនកម្មជាច្រើនក្នុងគោលបំណងពង្រឹងប្រព័ន្ធនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀតនៅដំណាក់កាលសវនាការ ។ សម្រាប់សវនាការនៅពេលអនាគត ដើមបណ្តឹងរដ្ឋប្បវេណីនឹងបង្កើតក្រុមរួមមួយ និងធ្វើការទាមទារសំណងខូចខាតរួម។ អ្នកតំណាងផ្នែកច្បាប់របស់ពួកគេនឹងត្រូវបានសម្របសម្រួលដោយមេធាវីនាំមុខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ការផ្លាស់ប្តូរទាំងនេះត្រូវបានធ្វើឡើងដើម្បីដោះស្រាយលើភាពខ្វះចន្លោះ ដែលបានជួបប្រទះនៅក្នុងសវនាការលើកដំបូងនៅ អវតក ។

3. ប៉ុន្តែ អង្គភាពគាំពារការការពារក្តីមានក្តីកង្វល់ចំបងពីរ ទាក់ទងទៅនឹងសិទ្ធរបស់ជនជាប់ចោទ ។ ទី១ ក្រោមប្រព័ន្ធថ្មីនេះ មេធាវីការពារក្តីចាញ់ប្រៀបយ៉ាងធ្ងន់ធ្ងរខាងផ្នែកធនធាន ។ ក្រុមមេធាវីនាំមុខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលមានមេធាវីចំនួន៨រូប នឹងត្រូវបានគាំទ្រដោយក្រុមមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ប្រហែល១០ ក្រុម) បន្ថែមទៀត ។ ដូច្នេះ ចំនួនមេធាវីសរុបមានយ៉ាងតិច៤០ នាក់ដែរ ក្នុងការតំណាងផលប្រយោជន៍ឲ្យដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការគាំទ្រដល់ការចោទប្រកាន់នេះ ។ នៅពេលរួមបញ្ចូលជាមួយមេធាវីពីការិយាល័យសហព្រះរាជអាជ្ញា នោះចំនួនអ្នកធ្វើការដើម្បីផ្តន្ទាទោសជនជាប់ចោទម្នាក់ កើនឡើងជាង ៥០ នាក់ឯណោះ ។

ចំនួននេះបើប្រៀបធៀបជាមួយក្រុមការពារក្តីនីមួយៗវិញ មានតែមេធាវី ៤ នាក់ប៉ុណ្ណោះ ។ ភាពគ្មានតុល្យភាពយ៉ាងខ្លាំងនៅក្នុងធនធានបែបនេះ ធ្វើឲ្យអន្តរាយដល់សមភាពនៃមធ្យោបាយការពារក្តី និងភាពត្រឹមត្រូវនៃដំណើរការនីតិវិធី តែប៉ុណ្ណោះ ។

4. ទីពីរ អង្គភាពគាំពារការការពារក្តីមានក្តីបារម្ភថា ការធ្វើវិសោធនកម្មនេះបានដកហូតនូវសិទ្ធិមួយចំនួនរបស់ជនជាប់ចោទ ក្នុងការតវ៉ាទៅនឹងភាពអាចទទួលយកបាននៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងជនជាប់ចោទ ។ ក្រោមប្រព័ន្ធថ្មីនេះ មេធាវីការពារក្តីត្រូវបានដកហូតសិទ្ធិក្នុងការប្តឹងតវ៉ាលើភាពអាចទទួលយកបាននៃការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅពេលសវនាការ ។ ជំនួសមកវិញ មេធាវីការពារក្តីមានពេលតែ ១០ ថ្ងៃដើម្បីប្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ចៅក្រមស៊ើបអង្កេតលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ប្រហែល ៤000 ពាក្យសុំ)។ ម្យ៉ាងវិញទៀត ប្រសិនបើជនត្រូវចោទអនុវត្តសិទ្ធិរបស់ខ្លួនដើម្បីប្តឹងតវ៉ាទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ជនត្រូវចោទត្រូវដាក់បណ្តឹឧទ្ធរណ៍ចំនួន ៤00 បណ្តឹងក្នុងមួយថ្ងៃ ជាពីរភាសា ។ វាពិតជាមិនអាចទៅរួចនោះទេ! អនុលោមទៅតាមបទដ្ឋានអន្តរជាតិ សិទ្ធិរបស់ជនជាប់ចោទក្នុងការប្តឹងឧទ្ធរណ៍ ត្រូវតែអាចអនុវត្តបាន និងមានប្រសិទ្ធិភាពក្នុងការអនុម័តលើការធ្វើវិសោធនកម្មទាំងនេះ កិច្ចប្រជុំពេញអង្គបន្សល់ទុកឲ្យជនជាប់ចោទនូវសិទ្ធិដែលមានតែទ្រឹស្តី តែប៉ុណ្ណោះ។